00599833

E188/14

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី ២

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស និងខ្មែរ (បកប្រែ)

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ៖

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 06 / 09 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

## សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី ២) លើសាលក្រមកាត់ទោសនិងសំណង

**ដាក់ដោយ៖**

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

**ផ្ញើជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ីម ជាប្រធាន

ចៅក្រម សោម សេរីវុឌ្ឍន៍

ចៅក្រម ស៊ិន រិទ្ធិ

ចៅក្រម យ៉ា ណារិន

ចៅក្រម Motoo Noguchi

ចៅក្រម Agniezska KLONOWIECKAMILART

ចៅក្រម Chandra Nihal Jayasinghe

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម JEAN-Marc LAVERGNE

ចៅក្រម ធូ មណី

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Phillipe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Pierre-Oliver SUR

លោកស្រី ទី ស្រីនណា

លោក Karim Khan

លោក Alain WERNER

លោកស្រី Brianne McGONIGLE

លោកស្រី Fabienne TRUSSES-NAPRUS

លោកស្រី Christine MARTINEAU

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ សូមដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង (វិ.លើកទី ៣) ជំនួសមុខឱ្យអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ លោក ប៊ូ ម៉េង (D25/1), លោកស្រី ឈិន ណារី (D25/2), លោក ជុំ ម៉ី (D25/3), លោក ជុំ ស៊ីវ៉ាត (D25/6), លោកស្រី ភីង ហ្គុតស៊ុនថារី (D25/5), លោកស្រី អ៊ឹម ស៊ុន្ធី (D25/7), លោក តាត់ ឡុន (D25/21), លោក ស៊ាង វ៉ាន់ឌី (D25/13), លោកស្រី អៀម សួយ (E2/ 21), លោក ស៊ីន លឹមសៀ (E2/25), លោកស្រី អ៊ុល សាយ ហៅ រាម (E2/24), លោកស្រី ពេញ សុខេន (E2/66) និងអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោមនៃក្រុម ២ ដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធពុំទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី មាន លោកស្រី ណាំ ម៉ុន (E2/32) លោក ស្រី ឆាយ កន *ហៅ* លៀង កន (E2/35) , លោកស្រី ហុង សាវ៉ាត (E2/83) , លោក ឈឹម ស៊ីថា (E2/22) និងលោកស្រី ញិប គីមស្រ៊ា (E2/64)។

យើងខ្ញុំបានដាក់ភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សរ ដែលបានអនុញ្ញាតឱ្យប្តឹងសាទុក្ខ[1]។

សំណើទាំងប៉ុន្មានរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ ដូចខាងក្រោមនេះ ត្រូវបានបដិសេធ[2]៖

- ការចងក្រង និងការផ្សព្វផ្សាយសេចក្តីថ្លែងសុំអភ័យទោស រួមទាំងយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើការសូមអភ័យទោសទាំងអស់នេះ[3]។
- សំណើទីពីរ៖ ការសរសេរលិខិតមួយច្បាប់ផ្ញើជូនរដ្ឋាភិបាល ស្នើសុំការសុំអភ័យទោសជាផ្លូវរដ្ឋ[4]។
- សំណើទីបី និងសំណើទីបួន៖ ការសាងសង់បូជនីយដ្ឋាននៅមន្ទីរ ស-២១ និងជើងឯក និងការប្រែក្លាយព្រៃស ឱ្យទៅជាបូជនីយដ្ឋាន[5]។
- សំណើទីប្រាំ៖ ការធ្វើទស្សនកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយការបង់ប្រាក់ជំនួស នៅតាមបូជនីយដ្ឋាននានា[6]។

---

1

2

3

4

5

6

- សំណើទីប្រាំមួយ៖ ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងសេវាចិត្តសាស្ត្រសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី[7]
- សំណើទីប្រាំពីរ៖ ការថតយកសំឡេង និងថតវីដេអូអំពីការជំនុំជម្រះក្តី[8]។
- សំណើទីប្រាំបី៖ ការយកឈ្មោះជនរងគ្រោះទៅដាក់ឈ្មោះអគារសាធារណៈចំនួន ១៧ និងពិធីបុណ្យ[9]
- សំណើទីប្រាំបួន៖ ការសរសេរលិខិតទៅរដ្ឋាភិបាល ស្នើសុំយកផ្ទៃចូលទស្សនាមន្ទីរ ស-២១ និងជើងឯកមួយផ្នែកសម្រាប់ការសងសំណង[10]។

អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") បានបដិសេធសំណើភាគច្រើន[11] និងទទួលយកតែមួយផ្នែកនៃសំណើទីមួយ ប៉ុន្តែបានបដិសេធការបោះពុម្ពផ្សាយមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការសុំអភ័យទោសទាំងនោះ[12]។

អនុលោមតាមវិធាន ១០៥ (៣) និង ១០៥ (២) (ក) និង (គ) នៃវិធានផ្ទៃក្នុង ភាគីដែលមានបំណងប្តឹងសាទុក្ខ ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។

## សេចក្តីសង្ខេបនៃមូលដ្ឋាននៃបណ្តឹងសាទុក្ខ

### I. មូលដ្ឋានទីមួយ

*ការបដិសេធសំណើនេះគឺផ្អែកតាមកំហុសអង្គច្បាប់ រំលោភគោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌នៃនីតិវិធី ក្នុងការសម្រេចដោយមានសំអាងហេតុ និងធ្វើឱ្យសាលក្រមនេះទៅជាមោឃៈ។*

១. អង្គជំនុំជម្រះសាលាដំបូងបានវិភាគរាល់គ្រប់សំណើសុំសំណងទាំង៣៦ របស់គ្រប់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់តែចំនួន ៩ កថាខណ្ឌប៉ុណ្ណោះ[13]។ ក្នុងការវិភាគនេះ អ.ជ.ស.ដ សង្ខេបសំណើទាំងអស់នោះ និងពុំចង្អុលបង្ហាញឱ្យច្បាស់ថាតើសំណើណាមួយត្រូវបានយកមកវិភាគត្រង់កថាខណ្ឌណាមួយឡើយ ហើយពុំបានលើកឡើងនូវសំណើទាំងនោះឡើយ។ ការផ្តល់សំអាង

7
8
9
10
11
12
13

ហេតុពុំពេញលេញគ្រប់គ្រាន់របស់ អ.ជ.ស.ជ នេះ រំលោភលើគោលការណ៍ច្បាប់ជាមូលដ្ឋាន ដែលថាគេត្រូវផ្តល់សំអាងហេតុឱ្យបានត្រឹមត្រូវចំពោះសេចក្តីសម្រេចណាមួយរបស់តុលាការ។

## II. មូលដ្ឋានទីពីរ

*ការបដិសេធសំណើទី១,ទី៣,ទី៤, និងទី៧ គឺផ្អែកតាមកំហុសអង្គច្បាប់/វិធានផ្ទៃក្នុង ដែលធ្វើឱ្យសាលក្រមក្លាយជាមោឃៈ ដោយបានរំលោភវិធាន ២១(១),២១(១)(ក),២១ (១)(គ) និង ២៣ នៃវិធានផ្ទៃក្នុង*

២. តុលាការគួរច្រានចោលការបដិសេធសំណើសុំសំណងទី ១, ទី៣,ទី៤, និងទី៧ ដោយហេតុថា អ.ជ.ស.ជ បានប្រព្រឹត្តកំហុសអង្គច្បាប់/វិធានផ្ទៃក្នុង នៅពេលខ្លួនពុំបានអើពើដល់អត្ថន័យខ្លឹមសារដ៏ច្បាស់លាស់នៃសំណើទាំងនោះ នៅពេលដែលខ្លួនបានបដិសេធសំណើទាំងអស់នោះចំពោះការខ្វះភាពច្បាស់លាស់។ តាមរយៈការបដិសេធសំណើទាំងនេះ អ.ជ.ស.ជ បានរំលោភភារកិច្ចរបស់ខ្លួនក្នុងការគាំពារផលប្រយោជន៍ជនរងគ្រោះ (វិ.២១ នៃវិធានផ្ទៃក្នុង) ធានាឱ្យមានភាពយុត្តិធម៌ (វិ.២១ (១)(ក)) និងគោរពសិទ្ធិជនរងគ្រោះ (វិ. ២១ (១)(គ))។ គ្មានមូលដ្ឋានគតិយុត្តិណាមួយសម្រាប់កម្រិតនៃភាពច្បាស់លាស់ដែលបានស្នើសុំឱ្យមាននោះឡើយ។

## III. មូលដ្ឋានទីបី

*ការបដិសេធសំណើទី២,៥,៨, និង៩ គឺផ្អែកតាមកំហុសអង្គច្បាប់/វិធានផ្ទៃក្នុង ដែលបានធ្វើឱ្យសាលក្រមក្លាយជាមោឃៈ និងរំលោភវិធាន ១០០(១)(វិ.លើកទី៣) នៃវិធានផ្ទៃក្នុង តាមរយៈការពុំសម្រេចពាក់ព័ន្ធនឹងសំណើទាំងនេះ*

៣. អ.ជ.ស.ជ ពុំវិភាគសំណើទី២,៥,៨ និង៩ ឡើយ ដូច្នេះនេះជាការរំលោភវិធាន ១០០ (១) នៃវិធានផ្ទៃក្នុងតាមរយៈការពុំសម្រេចលើការទាមទារទាំងអម្បាលម៉ានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អំពើអកម្មនេះគឺជាកំហុសអង្គច្បាប់/វិធានផ្ទៃក្នុង ដែលធ្វើឱ្យសាលក្រមគ្មានសុពលភាព ពាក់ព័ន្ធនឹងការបដិសេធសំណើទាំងអស់នេះ។

## IV. មូលដ្ឋានទីបួន

*ការបដិសេធសំណើទីប្រាំមួយគឺផ្អែកតាមកំហុសអង្គច្បាប់/វិធានផ្ទៃក្នុង ដែលនាំឱ្យសាលក្រមក្លាយជាមោឃៈ និងដែលបានរំលោភវិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង*

៤. សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ គឺបានធ្វើឡើងផ្អែកតាមការយល់ខុសចំពោះពាក្យថា "សំណងផ្លូវចិត្តជាសមូហភាព" ដូចដែលមានចែងក្នុងវិធាន ២៣(១)(ខ) ដោយបានចាត់ទុកសំណើនេះថាស្ថិតនៅក្រៅវង្វង់នៃសំណងនៅចំពោះមុខតុលាការ។

## V. មូលដ្ឋានទីប្រាំ

*ការបដិសេធសំណើទី៦ បានធ្វើឡើងផ្អែកតាមកំហុសអង្គច្បាប់/វិធានផ្ទៃក្នុង ដែលធ្វើឱ្យសាលក្រមក្លាយជាមោឃៈ និងដែលបានរំលោភវិធាន ២៣*

៥. បុរេលក្ខខណ្ឌនៃភស្តុតាងដែលបញ្ជាក់អំពីចំណងទាក់ទង រវាងវិធានការរបស់អ្នកទាមទារសំណង និងឧក្រិដ្ឋកម្មដែលតុលាការបានរកឃើញថាស្ថិតក្រោមការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ តាមការតម្រូវរបស់ អ.ជ.ស.ដ គ្មានមូលដ្ឋានគតិយុត្តិទេ ទាំងក្នុងផ្នែកច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

## VI. មូលដ្ឋានទីប្រាំមួយ

*ការបដិសេធសំណើទី១,២,៣,៤,៥,៧,៨, និង៩ គឺផ្អែកតាមកំហុសអង្គច្បាប់ ដែលបាននាំឱ្យមានការសម្រេចដោយអយុត្តិធម៌*

៦. តាមរយៈការពុំចេញសេចក្ដីសម្រេចណាមួយលើសំណើទី២ និងទី៩ ឬការពុំអើពើនឹងអត្ថន័យដ៏ច្បាស់លាស់នៃសំណើទាំងនេះ ឃើញថាសេចក្ដីសម្រេចរបស់ អ.ជ.ស.ដ គឺបានធ្វើឡើងផ្អែកតាមកំហុសអង្គហេតុ។

៧. តាមរយៈការបដិសេធសំណើទី១,៣,៤ និងទី៧ ដោយហេតុថាសំណើទាំងនោះខ្វះភាពជាក់លាក់ ទោះជាសំណើទាំងនោះមានលក្ខណៈលម្អិតគ្រប់គ្រាន់ទៅហើយក្ដី ក៏សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ត្រូវបានធ្វើឡើងផ្អែកតាមកំហុសអង្គហេតុដែរ។

៨. តាមរយៈការពុំចេញសេចក្តីសម្រេចណាមួយលើសំណើទី៥ និងទី៨ អ.ជ.ស.ជ បានប្រព្រឹត្ត កំហុសអង្គហេតុ។

## V. សន្និដ្ឋាន

៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងដាក់ជូនទូវមូលដ្ឋានសំខាន់ៗនៃបណ្តឹងសាទុក្ខ ក្នុង អំឡុងពេល៦ថ្ងៃ នៃការជូនដំណឹងអំពីបណ្តឹងសាទុក្ខនេះ។

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងស្នើសុំឲ្យ

- ប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍នេះ
- ច្រានចោលការបដិសេធសំណើទាមទារសំណង និង
- ផ្តល់សំណងតាមការស្នើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២។

លោក ហុង គីមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

ធ្វើនៅភ្នំពេញថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ។